ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ......សហវ.ប្រក

# ប្រកាស

## ស្តីពី

## វិធាននិងនីតិវិធីសម្រាប់អនុវត្ត ពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេស

## ទេសរដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសារពើពន្ធ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St,92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរសព្ទ៍ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone: 855-23-724 664 Fax: 855-23-427 798

## សម្រេច

**ប្រការ ១.- គោលបំណង**

ប្រកាសនេះ មានគោលបំណងណែនាំអនុវត្តពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេស ស្របតាមមាត្រា២២ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ ដែលត្រូវបានធ្វើវិសោធនកម្មដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧។

**ប្រការ ២.- គោលដៅ**

ប្រកាសនេះ មានគោលដៅកំណត់ឱ្យបានច្បាស់លាស់នូវវិធាននិងនីតិវិធីសម្រាប់ណែនាំអនុវត្តពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេស ដូចមានចែងក្នុងមាត្រា២២ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ៣.- វិសាលភាព**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះសាខាក្រុមហ៊ុនបរទេសដែលប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ៤.- និយមន័យ**

សម្រាប់គោលដៅនៃប្រកាសនេះ ពាក្យ "សាខាក្រុមហ៊ុនបរទេស" សំដៅដល់ ទីកន្លែងប្រកបអាជីវកម្មជាប់លាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជារបស់ក្រុមហ៊ុនបរទេស ដែលក្នុងនោះទ្រព្យសកម្មផ្សេងៗគឺជារបស់ក្រុមហ៊ុនដើមនៅបរទេស។

**ប្រការ ៥.- ប្រាក់ចំណូលជាប់ពន្ធ**

អនុលោមតាមកថាខណ្ឌ៤ នៃមាត្រា៣ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ សាខាក្រុមហ៊ុនបរទេស ត្រូវជាប់ពន្ធលើប្រាក់ចំណូលចំពោះតែប្រាក់ចំណូលប្រភពកម្ពុជាប៉ុណ្ណោះ។ ប្រាក់ចំណូលជាប់ពន្ធ គឺជាប្រាក់ចំណូលបានមកពីការប្រកបអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា កាត់កងនូវចំណាយនានាដែលអនុញ្ញាតដោយបទប្បញ្ញត្តិនៃផ្នែកទី៣ នៃជំពូកទី១ នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ៦.- ការគណនាពន្ធលើប្រាក់ចំណូល**

ពន្ធលើប្រាក់ចំណូលសម្រាប់សាខាក្រុមហ៊ុនបរទេសសម្រាប់ឆ្នាំជាប់ពន្ធណាមួយ ត្រូវបានគណនាដោយយកប្រាក់ចំណូលជាប់ពន្ធក្នុងឆ្នាំជាប់ពន្ធនោះ ទៅគុណនឹងអត្រាពន្ធដូចមានចែងក្នុងមាត្រា២០ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ៧.- ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភ**

ប្រសិនបើនៅក្នុងឆ្នាំជាប់ពន្ធចរន្ត សាខាក្រុមហ៊ុនបរទេសធ្វើការបែងចែកប្រាក់ចំណូលរក្សាទុកទៅឱ្យក្រុមហ៊ុនដើមនៅបរទេស ប្រាក់ចំណូលនោះ÷

១- មិនត្រូវជាប់ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភតាមមាត្រា២៣ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធទេ ប្រសិនបើប្រាក់ចំណូលដែលផ្ទេរនោះជាប្រាក់ចំណូលក្រោយការបង់ពន្ធលើប្រាក់ចំណូលតាមកថាខណ្ឌ១ ឬកថាខណ្ឌ២ នៃមាត្រា២០ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ។

២- ត្រូវជាប់ពន្ធលើប្រាក់ចំណូលបន្ថែមលើការបែងចែកភាគលាភតាមកថាខណ្ឌ១ នៃមាត្រា២៣ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ ប្រសិនបើប្រាក់ចំណូលដែលផ្ទេរនោះជាប្រាក់ចំណូលដែលមិនបានបង់ពន្ធលើប្រាក់ចំណូលតាមកថាខណ្ឌ១ ឬកថាខណ្ឌ២ នៃមាត្រា២០ថ្មី (មួយ) នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ៨.-** **ពន្ធកាត់ទុកលើប្រាក់ចំណូលប្រភពកម្ពុជា**

នៅពេលសាខាក្រុមហ៊ុនបរទេសផ្ទេរប្រាក់ចំណូលប្រភពកម្ពុជាទៅឱ្យក្រុមហ៊ុនដើមនៅបរទេស ត្រូវកាត់ទុកនិងបង់នូវប្រាក់ពន្ធចំនួន ១៤ ភាគរយ នៃទឹកប្រាក់ត្រូវផ្ទេរ ស្របតាមមាត្រា២៦ថ្មី (មួយ) និងកថាខណ្ឌ ១០ នៃមាត្រា៣៣ថ្មី នៃច្បាប់ស្តីពីសារពើពន្ធ។

**ប្រការ ៩.-** **ពន្ធអាករដទៃទៀត**

ក្រៅពីពន្ធលើប្រាក់ចំណូល សាខាក្រុមហ៊ុនបរទេសត្រូវបង់ពន្ធអាករដទៃទៀត ស្របតាមច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមាន នៃព្រះរាជាណាចក្រកម្ពុជា។

**ប្រការ ១០.-** **កាតព្វកិច្ចដាក់លិខិតប្រកាសនិងបង់ប្រាក់ពន្ធ**

សាខាក្រុមហ៊ុនបរទេសត្រូវមានកាតព្វកិច្ចដាក់លិខិតប្រកាស និងបង់ប្រាក់ពន្ធអាករប្រចាំខែ ប្រចាំឆ្នាំ តាមកាលកំណត់ ជូនរដ្ឋបាលសារពើពន្ធ។

**ប្រការ ១១.-** **ការអនុវត្ត**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១៧

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ ១១ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ